មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

លេខ:.014.68/12...../ម.ស.ម.ក/

លិខិតចំហរ

សូមគោរពជូន
ឯកឧត្តម ង៉ូ ប៊ុនឆេង
ប្រធានសាលាឧទ្ធរណ៍

កម្មវត្ថុ៖ លិខិតផ្ញើជូនសាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជាស្នើសុំពន្លឿនសំណុំរឿងឧទ្ធរណ៍របស់ លោក ម៉ម សូណង់ដូ

ខ្ញុំសូមជម្រាបឯកឧត្តមមេត្តាជ្រាបអំពីករណីលោក ម៉ម សូណង់ដូ ជានាយកវិទ្យុសំបុកឃ្មុំ និងជាប្រធានសមាគមប្រជាធិបតេយ្យ៖ លោក ម៉ម សូណង់ដូ ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១២ និងត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ននៅពន្ធនាគារព្រៃសរ រាជធានីភ្នំពេញ។ នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០១២ សាលាដំបូងរាជធានីភ្នំពេញបានរកឃើញថា លោកមានពិរុទ្ធិភាពដូចការចោទប្រកាន់ប្រឆាំងរូបលោក ទាក់ទងបទល្មើសមួយចំនួន ដែលរួមមានបទល្មើសទាក់ទងនឹងការញុះញង់ឲ្យមានចលនាអបគមន៍ នៅខេត្តក្រចេះ និងញុះញង់ប្រជាពលរដ្ឋឲ្យប្រឆាំងរាជរដ្ឋាភិបាល ហើយក្រោយមកលោកត្រូវបានតុលាការសម្រេចផ្តន្ទាទោសឲ្យជាប់ពន្ធនាគារចំនួនម្ភៃ (២០)ឆ្នាំ។

ដោយសារតែកិច្ចប្រជុំកំពូលអាស៊ាន នឹងឈានចូលមកដល់នាពេលឆាប់ៗខាងមុខ ដែលនឹងមានការចូលរួមដោយឥស្សរៈជនបរទេសសំខាន់ៗជាច្រើនរូប រួមមានប្រធានាធិបតីសហរដ្ឋអាមេរិក លោកបារ៉ាក់ អូបាម៉ាជាដើម ដូច្នេះហើយខ្ញុំស្នើសុំឯកឧត្តមប្រធានមេត្តាជួយសំរួលពន្លឿនសំណុំរឿងឧទ្ធរណ៍របស់លោកម៉ម សូណង់ដូ ឲ្យបានឆាប់រហ័សនាពេលខាងមុខនេះ។ ការផ្តន្ទាទោសដាក់ពន្ធនាគារមួយជីវិតដល់រូបលោកដែលមានអាយុចិតសិបមួយ (៧១) ឆ្នាំ គឺធ្វើឡើងដោយពុំមានភស្តុតាងរឹងមាំច្បាស់លាស់នោះឡើយ។ ការសម្រេចសាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ បានបង្ហាញពីភាពមិនប្រក្រតីនៃឯករាជ្យភាព និងភាពយុត្តិធម៌នៃប្រព័ន្ធតុលាការកម្ពុជានាពេលបច្ចុប្បន្ន។

អាសយដ្ឋាន ផ្ទះលេខ ៣៩៨ ផ្លូវលេខ ៩៩, សង្កាត់បឹងត្របែក ខណ្ឌចំការមន, ប្រអប់សំបុត្រលេខ ២៥១៥, រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ: ០២៣ ៣២៦ ៩០១ ទូរសារ: ០២៣ ៣២៦ ៩០២ អ៊ីមែល: info@cchrcambodia.org វេបសាយ: www.cchrcambodia.org

ករណីរបស់លោកម៉ម សូណង់ដូត្រូវបានសកលលោកស្រែកថាអយុត្តិធម៌ ហើយទាំងសហគមន៍ជាតិនិងអន្តរជាតិបានទាមទារឲ្យមានសេចក្តីសម្រេចដ៏យុត្តិធម៌ពិតប្រាកដមួយចំពោះរូបលោក។ ប្រទេសជាច្រើន រួមមាន សមាជិកសភាសហភាពអ៊ឺរ៉ុប ក្រសួងការបរទេសសហរដ្ឋអាមេរិក និងក្រសួងការបរទេសបារាំងជាថ្មីម្តងទៀតបានលើកឡើងថា កម្ពុជាត្រូវតែពង្រឹងនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យរបស់ខ្លួន អោយបានពិតប្រាកដ និងត្រូវតែគោរពសិទ្ធិមនុស្សឲ្យបានត្រឹមត្រូវ។ ការវិនិច្ឆ័យជាថ្មីរបស់សាលាឧទ្ធរណ៍ជាឱកាសសំខាន់មួយសម្រាប់តុលាការកម្ពុជា ក្នុងការធានាអំពីសិទ្ធិមូលដ្ឋានរបស់ប្រជាពលរដ្ឋកម្ពុជា និងការបែងចែកអំណាច ដែលជាមូលដ្ឋានគ្រឹះនៃលទ្ធប្រជាធិបតេយ្យ។

ខណៈដែលព្រះរាជាណាចក្រកម្ពុជា នឹងធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលអាស៊ានលើកទី២១ ប្រកបដោយមោទនភាព កម្ពុជាត្រូវតែអនុលោមទៅតាមគោលការណ៍ ដែលមានចែងនៅក្នុងធម្មនុញ្ញ អាស៊ាន រួមមានការពង្រឹងប្រព័ន្ធយុត្តិធម៌ និងនីតិរដ្ឋ។ ដើម្បីបង្ហាញថា កម្ពុជាប្រកាន់ភ្ជាប់កាតព្វកិច្ចធានានូវសិទ្ធិជំរុំជម្រះក្តីដោយយុត្តិធម៌ នៅក្រោមច្បាប់ជាតិ និងអន្តរជាតិ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាស្នើសុំឯកឧត្តមប្រធានមេត្តាប្រើអស់សមត្ថភាពដើម្បីពន្លឿននូវសំណុំរឿងឧទ្ធរណ៍របស់លោកម៉ម សូណង់ដូ ទៅតាមពេលវេលាសមស្របណាមួយ និងសូមផ្តល់យុត្តិធម៌ ដល់លោកដែលសមនឹងទទួលបាន។

សូម ឯកឧត្តមប្រធានមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១២

ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

អ៊ូ ទីរ៉ះ